# សាសនា ឬ ចិត្តវិញ្ញាណ

## *Religion or Spiritual*

តាមនិយមន័យពាក្យថា religion ដែលមានឫសពាក្យមកពីភាសាឡាតាំងបុរាណមានន័យថា "*ជំនឿទៅលើព្រះអាទិទេព វត្ថុអរូបីយ៍ ឬការថ្វាយខ្លួនជាអ្នកបំរើចំពោះអាទិទេព្យនិងវត្ថុអរូបីយ៍នោះ* " (the service and worship of God or the supernatural) ។ តែបើក្រលេកមកមើលពាក្យថា សាសនវិញ តាមភាសាបាលីមានន័យថា "*ពាក្យប្រៀនប្រដៅ ឬ ពាក្យអប់រំទូន្មានដែលឈរនៅលើសច្ចះភាពពិត* "។ បានជាលើកយកពាក្យខុសគ្នារវាងជីវិតលើសាសនា ឬជីវិតខាងចិត្តវិញ្ញាណមកអធិប្បាយនៅទីនេះ ព្រោះសព្វថ្ងៃនៅបច្ចឹមប្រទេសមានគេប្រើច្រើន ហើយនិយមច្រើនក្នុងការដឹកនាំជីវិតរបស់គេ ខាងទីពឹងទៅលើផ្លូវចិត្តវិញ្ញាណ។ បានជាមានបាតុភូតដូច្នេះកើតឡើង យើងអាចគិត ហើយសន្និដ្ឋានទៅលើបញ្ហាសំខាន់ៗដូចជា :

- មនុស្សដែលមានបញ្ញាខ្លាំងចាប់ផ្តើមផ្តោតអារម្មណ៍ទៅលើការប្រើសតិបញ្ញានិងលើកកំពស់សក្តានុពល(potentiality)របស់មនុស្សជាជាងជឿទៅលើវត្ថុអរូបីយ៍និងការបួងសួងអង្វរករដោយឥតន័យ ។
- មានផលអាក្រក់ចំពោះជំនឿលើអាទិទេព ឬព្រះជាម្ចាស់ ដែលមានភស្តុតាងប្រាកដច្បាស់នៅលើទំព័រប្រវត្តិសាស្រ្ត ដូចជាបញ្ហាសង្រ្គាមសាសនា(Crusade) សង្រ្គាមជីហាត់ (Jihad) ការដាក់គ្រាប់បែកធ្វើអត្តឃាត(Suicide Bombing)ក្នុងនាមព្រះជាម្ចាស់ និងមូលហេតុអន្តរាយដទៃផ្សេងទៀត ដែលកើតមកអំពីឧបាទាន(Attachments) ដែលជាហេតុនាំទៅរកការប្រកាន់ជ្រុល(Extremes)។
- ជីវិតប្រចាំថ្ងៃពិតប្រាកដ ទាំងបញ្ហាសុខភាពផ្លូវកាយ ផ្លូវចិត្ត សេដ្ឋកិច្ចគ្រួសារ និងសន្តិភាព មិនបានផុសចេញពីមូលដ្ឋានលើជំនឿអាទិទេពទាំងស្រុងទេ។ ផ្ទុយទៅវិញសាសនាដែលឈរលើជំនឿអាទិទេពរមែងប្រកាន់នូវភាពមានពិតនៃអាទិទេពរបស់ខ្លួនរៀងៗខ្លួនព្រមទាំងមិនអាចមានភាពអត់ធន់(ខន្តិធម៌)នូវទំនាស់នេះបាន ហើយរមែងប្រហាត់ប្រហារ

គ្នាដោយឥតឈប់ឈរ។ ជាក់ស្តែងសាសនាអ៊ីស្លាមជាមួយយេស៊ូគ្រីស្ត ហិណ្ឌូជាមួយអ៊ីស្លាម អ៊ីស្លាមនិកាយស៊ីអ៊ិ(Shii)និងនិកាយស៊ុននី(Sunny) ឬ ទោះបីសាសនាយេស៊ូគ្រីស្តនិកាយកាតូលិច(Catholic) និងនិកាយប្រូតេស្តង់ (Protestant) ជាដើម។

ចុះហេតុអ្វីបានជាមនុស្សចាប់ផ្តើមជឿទៅលើជីវិតខាងចិត្តវិញ្ញាណ? ចំឡើយដែលងាយគឺវាងាយក្នុងការរស់នៅ លើកកំពស់សក្តានុពលរបស់មនុស្ស ហើយជាពិសេសគឺងាយសំរបខ្លួនឱ្យចូលជាមួយអ្នកដទៃនៅក្នុងសង្គមពហុវប្បធម៌ ពហុជាតិសាសន៍ ពហុភាសា និងពហុសាសនា ឬដែលគេនិយមហៅថា "ការលើកស្ទួយសហគមន៍ "(community facilities) ។

ចុះតើព្រះពុទ្ធសាសនាឈរនៅត្រង់ណា រវាងសាសនានិងចិត្តវិញ្ញាណ?

អាចឆ្លើយបានយ៉ាងងាយថា ព្រះពុទ្ធសាសនាមានជំហរទាំងសងខាងប្រកបដោយតុល្យភាពរវាងគ្នានិងគ្នា។ បានជាឆ្លើយដូច្នេះព្រោះមានហេតុផលសំខាន់៧ដូចជា :

*ព្រះពុទ្ធសាសនាគឺជាសាសនា* (Buddhism as a Religion)

- មានអង្គប្រកបគ្រប់៥យ៉ាងដែលជាឫសគល់របស់សាសនាទាំងអស់គឺ

១. សាសតា : ព្រះសម្មាសម្ពុទ្ធជាម្ចាស់

២. សាសនធម៌: ព្រះធម៌ព្រះអង្គបង្រៀនទាំង៨៤០០០ព្រះធម្មក្ខន្ធ រួមចងក្រងជាគម្ពីរព្រះត្រៃបិដកមានដល់សព្វថ្ងៃ ហើយប្រែចេញរាប់រយភាសា ។

៣. សាសនាទាយាទ : មានពុទ្ធបរិស័ទបួន គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា

៤. សាសនពិធី: មានពិធីកម្មសំខាន់ជាច្រើនដូចជាថ្ងៃពិសាខបូជា មាឃបូជា អាសាឍបូជា ចេញព្រះវស្សា ចូលព្រះវស្សា ការបួសនាគ ការធ្វើបុណ្យទក្ខិណានុប្បទាន បុណ្យបច្ច័យបួន ការរក្សាសីល សូត្រមន្ត នមស្សការ និងបុណ្យជាច្រើនផ្សេងទៀត។

៥. សាសនស្ថានៈ គឺមានសង្វេជនីយដ្ឋានបួនដូចជាទីព្រះអង្គប្រសូត្រ ទីព្រះអង្គត្រាស់ដឹង ទីព្រះអង្គសំដែងបឋមទេសនា វត្តអារាម សារីរិកធាតុ ចេតិយ៍ ដើមពោធិព្រឹក្ស។

- មានការបូជា និងជំនឿទៅលើភពទេវតា ព្រហ្ម ការកើតម្តងទៀត
- មានព្រះពោធិសាត់ ពុទ្ធភូមិ ព្រះនិព្វានជាគោលដៅ។

*ព្រះពុទ្ធសាសនាជាចិត្តវិញ្ញាណ* (Buddhism as a Spiritual)

- ព្រះពុទ្ធសាសនាប្រែថា ពាក្យប្រៀនប្រដៅប្រកបដោយសច្ចធម៌របស់ព្រះពុទ្ធ ហើយមិនបានផ្តល់ភាពសំខាន់ទៅលើជំនឿការបួងសួងអង្វរករឬការថ្វាយខ្លួនជាអ្នកបំរើចំពោះអាទិទេពឬវត្ថុអរូបីយ៍ណាមួយទេ ។
- ព្រះពុទ្ធសាសនាសង្កត់ធ្ងន់ទៅលើតុល្យភាពរវាងបញ្ញានិងសទ្ធា
- លើកកិរិតសក្តានុពលរបស់មនុស្សជាមជ្ឈមណ្ឌល (centred on human beings, not on Gods/God or superstitions)
- ប្រកាន់ខ្ជាប់នូវខន្តិធម៌ អហិង្សធម៌ មេត្តាធម៌ និងមិនដែលមានស្លាកស្នាមការប្រហាត់ប្រហារគ្នា ក្នុងនាមសាសនាដោយពុទ្ធសាសនិកជនឡើយ។
- មានសមាធិដែលជាប្រភពនៃបញ្ញា សេចក្តីសុខ សុខភាពនិងការព្យាបាលរោគ
- មានគោលធម៌ដែលមានសារៈប្រយោជន៍សំរាប់អ្នកស្រាវជ្រាវ អ្នកចិត្តវិទ្យា អ្នកប្រាសាទវិទ្យា អ្នកវិទ្យាសាស្រ្ត និង អ្នកសង្គមវិទ្យា។
- មានសេចក្តីពិតគឺអរិយសច្ច៤ ជាសច្ចភាពសាកល ។

ទោះបីយ៉ាងណាក៏ដោយ មានអ្នកទេវនិយមជាច្រើន បានចោទប្រកាន់ព្រះពុទ្ធសាសនាថាគឺគ្រាន់តែជាទស្សនវិជ្ជាជីវិត ព្រោះមិនសង្កត់ធ្ងន់ទៅលើជំនឿរឿងអាទិទេព ឬវត្ថុសក្តិសិទ្ធិមានយ៉ាងសំងាត់នៅក្រៅខ្លួន។ តែតាមការពិតសេចក្តីសុខប្រចាំថ្ងៃ សន្តិភាព ការសំរេចធម៌ជាន់ខ្ពស់ និងព្រះនិព្វាន មិនបានស្ថិតនៅលើជំនឿទៅលើវត្ថុក្រៅខ្លួន ការជួយពីអ្នកដទៃទេ តែស្ថិតនៅលើសេចក្តីព្យា

យាមរបស់បុគ្គលម្នាក់ៗ ដោយឈរនៅលើសម្មាទិដ្ឋិ សម្មាសង្កប្ប: និងការមានអធិដ្ឋានចិត្តដ៏ខ្លាំងក្លាមោះមុតមួយ ។

ឧទាហរណ៍ព្រះជនក ដែលលិចសំពៅនៅកណ្តាលមហាសមុទ្រឥតកោះត្រើយ មិនបានមាននរណាមកជួយស្រោចស្រង់ព្រះមហាជនកទេ មានតែព្រះមហាជនកខ្លួនឯងដែលខំព្យាយាមហែលទឹករហូតដល់កក្រើកដល់អស់ពួកទេវតាមារព្រហ្មទាំងឡាយ។ នេះជាសេចក្តីពិត បើថ្ងៃណាមួយយើងធ្លាក់ទឹក ហើយយើងពុំបានហ្វឹកការហែលទឹក ឬក៏មិនបានព្យាយាមស្រវេស្រវាហែល តែយើងមានជំនឿទៅលើព្រះ ឬព្រះអាទិទេពអង្គណាមួយ រួចស្រែកសុំជំនួយពីព្រះទាំងអស់នោះឱ្យមកជួយ ក៏គង់តែព្រះទាំងអស់នោះមកជួបយើងនៅឋានបាតទឹកជាក់ជាមិនខាន។ ឬក៏អាចមិនយល់ឃើញសេចក្តីពិតនៅតែនឹកគិតដល់ថ្ងៃប្រល័យលោក បើនរណាជឿព្រះនឹងមានគេស្រង់ដាក់លើទូកដូច្នោះ ប្រហែលជាដូចគ្នានឹងពាក្យខ្មែរថា "*កាប់បំពង់រង់ចាំទឹកភ្លៀង ឬ ក្រាលកន្ទេលរង់ចាំអ្នកមានបុណ្យ*"។

ជាសរុប ព្រះពុទ្ធសាសនាប្រកាន់ខ្ជាប់នូវទ្រឹស្តីនិងការបដិបត្តិជាផ្លូវកណ្តាល គឺមិនជ្រុលទៅផ្នែកម្ខាងៗទេ ដរាបណាទ្រឹស្តីឬការបដិបត្តិនោះមិនត្រូវបានស្រាវជ្រាវ ពិសោធន៍ រកហេតុបច្ច័យរបស់វាច្បាស់លាស់។ ដូច្នេះ ព្រះពុទ្ធសាសនាគឺជាសាសនា (Religion) ជាចិត្តវិញ្ញាណ (Spiritual) ជាទស្សនវិជ្ជា(Philosophy) ជាសាសនាជីវិត(Life Religion) ជាវិទ្យាសាស្ត្រ (Science) ជាសង្គមសាស្ត្រ(Sociology) ជាចិត្តសាស្ត្រ(Psychology) ជាវិជ្ជាស្ថាននៃសតិបញ្ញានៃហេតុនិងផល(Institute of intelligence of Rationalistic) និងឈរនៅលើសេចក្តីពិត គឺអរិយសច្ចធម៌(Noble truth) ។